00414148

D140/4/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ ២៨)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 12 / 2009
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

**កាលបរិច្ឆេទ:** ១៤ ខែវិច្ឆិកា ឆ្នាំ២០០៩

---

## សាធារណៈ(ដោយកោសលុប)

## សាលដីកាលើពាក្យបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម

---

**សហព្រះរាជអាជ្ញា**
ជា លាង
William SMITH
យ៉េត ចរិយា
សេង ប៊ុនឃាង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២៨)

លេខ/No D140/4/5

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន
ឡោ ជុនធី
នី ចាន់ដា
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ិន ស៊ីវ៉ន
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BEAUDOIN
Marie GUIRAUD
LYMA NGUYEN

**សហមេធាវីការពារជនត្រូវចោទ**

សហមេធាវីការពារ អៀង សារី
អាង ឧត្តម
Michael G. KARNAVAS

**សហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង
Marcel Lemonde

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00414150

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”)បានទទួល “ពាក្យបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម” ដែលបានដាក់ដោយសហមេធាវីការពារក្តីជនត្រូវចោទអៀង សារី (“ជនត្រូវចោទ”) កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (“បណ្តឹងឧទ្ធរណ៍”)[១]។

## **ប្រវត្តិ**

១. កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ សហមេធាវីការពារក្តីជនត្រូវចោទ នួន ជា បានដាក់ “សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយ” របស់ខ្លួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (“សំណើសុំលើកទីប្រាំមួយរបស់ នួន ជា”)[២]។ សំណើសុំលើកទីប្រាំមួយរបស់ នួន ជា បានស្នើសុំ “សហចៅក្រមស៊ើបអង្កេតឱ្យព្យាយាមកំណត់[redacted] - [redacted]”[៣]។ លើសពីនេះទៀត សំណើនោះ បានស្នើសុំឱ្យមានការតែងតាំងអ្នកជំនាញបែបនេះចំនួនមួយរូប ឬច្រើនរូប[៤]។

---

[១] បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម ដែលបានដាក់កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ (“បណ្តឹងឧទ្ធរណ៍”) ឯកសារ D140/4/1។

[២] “សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយ” ដែលបានដាក់កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ (“សំណើសុំលើកទីប្រាំមួយរបស់ នួន ជា”) ឯកសារ D113។

[៣] “សំណើសុំលើកទីប្រាំមួយរបស់ នួន ជា” កថាខណ្ឌទី៩។

[៤] “សំណើសុំលើកទីប្រាំមួយ របស់ នួន ជា” កថាខណ្ឌទី១។

២. នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២00៨ សហចៅក្រមស៊ើបអង្កេតបានធ្វើការឆ្លើយតបជាវិជ្ជមានទៅនឹងសំណើសុំលើកទីប្រាំមួយរបស់ នួន ជា[៥] និងបានតែងតាំងលោកបណ្ឌិត Ewa Maria Tabeau និងលោក ថី ឃាម (They Kheam) [redacted] ដើម្បីធ្វើសេចក្តីរាយការណ៍ត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២00៨[៦]។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២00៨ សហចៅក្រមស៊ើបអង្កេតបានពន្យារពេលវេលាកំណត់សម្រាប់ការដាក់របាយការណ៍របស់អ្នកជំនាញ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២00៨[៧]។

៣. នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២00៨ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់ "សំណើរបស់ អៀង សារី [redacted]" ("សំណើសុំរបស់ អៀង សារី")[8] នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ មូលដ្ឋានសម្រាប់ការស្នើសុំនេះ គឺថា លោកបណ្ឌិត Tabeau ខ្វះភាពអនាគតិ និងសមត្ថភាព និងថាសហចៅក្រមស៊ើបអង្កេតមិនបានពិគ្រោះយោបល់ជាមួយសហមេធាវីការពារក្តីជនត្រូវចោទ មុនពេលតែងតាំងអ្នក[redacted]នេះទេ[៩]។

៤. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២00៨ សហចៅក្រមស៊ើបអង្កេតបានបដិសេធលើសំណើសុំរបស់ អៀង សារី[១០]។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា "ពុំមានភស្តុតាងដែលអាចនាំឱ្យមានការសង្ស័យសមហេតុផលអំពីភាពអនាគតិ ឬសមត្ថភាព" របស់លោកបណ្ឌិត Tabeau នោះទេ និង

---

[៥] "ចម្លើយតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយ (ឯកសារ D113) និងចម្លើយតបផ្នែកខ្លះទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំ (ឯកសារ D105)" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២00៨ ឯកសារ D113/2 និង D105/2។

[៦] "ដីកាចាត់តាំងអ្នកជំនាញ" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២00៨ ឯកសារ D140។

[៧] "កំណែនៃដីកាចាត់តាំងអ្នកជំនាញ" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២00៨ ឯកសារ D140/1។

[៨] "សំណើរបស់ជនត្រូវចោទ អៀង សារី សុំ[redacted]" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២00៨ ("សំណើរបស់ អៀង សារី") ឯកសារ D140/2។

[៩] សំណើរបស់ អៀង សារី កថាខណ្ឌទី៥។

[១០] "ដីកាសម្រេចលើសំណើ[redacted]" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២00៨ ("ដីកា") ឯកសារ D140/3។

បានប្រកាសថា ស្របតាមវិធានផ្ទៃក្នុង ក.ស.ច.ស មិនមានកាតព្វកិច្ចក្នុងការពិគ្រោះយោបល់ជាមួយភាគីនានា មុនពេលតែងតាំងអ្នកជំនាញនោះទេ[១១]។

៥. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍នោះ សហមេធាវីការពារក្តីជនត្រូវចោទស្នើសុំបើកសវនាការដេញដោលផ្ទាល់មាត់[១២]។ នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ ដែលបានដាក់កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាមិនយល់ព្រមតាមសំណើសុំនោះទេ ដោយបានលើកទឡ្ហីករណ៍ថា សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ គឺធ្វើឡើងដោយការយល់ខុស និងពុំមានភស្តុតាងគាំទ្រដែលអាចជឿជាក់បាននោះទេ[១៣]។ សហព្រះរាជអាជ្ញា បានស្នើសុំថែមទៀតឱ្យធ្វើការកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ ដោយមិនចាំបាច់មានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈនោះទេ[១៤]។

៦. បន្ទាប់ពីការដាក់ពាក្យបណ្តឹងឧទ្ធរណ៍មក លោកបណ្ឌិត Tabeau និងលោក ថឺ ឃាម បានដាក់រួមគ្នានូវរបាយការណ៍របស់[redacted]របស់ខ្លួន កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩[១៥]។

៧. នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានសម្រេចធ្វើការកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ ផ្អែកតាមសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ និងបានណែនាំឱ្យសហមេធាវីការពារក្តី

---

[១១] ដីកា កថាខណ្ឌទី១៤ ដល់១៥។

[១២] ដីកា កថាខណ្ឌទី៨ ដល់១០។

[១៣] "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់ អៀង សារី ប្រឆាំងនឹងការបដិសេធសំណើសុំរបស់គាត់ដោយសហចៅក្រមស៊ើបអង្កេតអំពីការតែងតាំង[redacted]" ដែលបានដាក់កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") ឯកសារ D140/4/2 កថាខណ្ឌទី៣។

[១៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌទី៤ ដល់ទី៨។

[១៥] "របាយការណ៍របស់[redacted] ជនរងគ្រោះនៅប្រទេសកម្ពុជា ខែមេសា ឆ្នាំ១៩៧៥ - ខែមករា ឆ្នាំ១៩៧៩ ការវាយតម្លៃទិតៀនលើការប៉ាន់ប្រមាណសំខាន់ៗ" ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D140/...



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ជនត្រូវចោទធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅក្នុងរយៈពេលកំណត់ ដែលបានចែងនៅក្នុងមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/ វិសោធនកម្ម លើកទីបួន[១៦]។ ពុំមានការឆ្លើយតបណាមួយត្រូវបានដាក់នៅក្នុងរយៈពេលកំណត់នេះទេ។

## ភាពអាចទទួលយកបាន

៨. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើសំណើរបស់ជនត្រូវចោទសុំ[redacted]បន្ថែម។ ដីកានោះត្រូវបានជូនដំណឹងដល់ជនត្រូវចោទ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍។ សារណាបណ្តឹងឧទ្ធរណ៍ ត្រូវបានដាក់ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ និងនៅក្នុងរយៈពេលកំណត់ដែលបានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

៩. អង្គបុរេជំនុំជម្រះ សង្កេតឃើញថា បណ្តឹងឧទ្ធរណ៍និយាយអំពីសំណើសុំដែលបានដាក់ស្របតាម វិធាន ៣១(១០) នៃវិធានផ្ទៃក្នុង ដែលបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត និងសង្កេតឃើញថា សហមេធាវីការពារក្តីបានអះអាងថា ពាក្យបណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ពីព្រោះ "នៅពេលដែលសហចៅក្រមស៊ើបអង្កេតបដិសេធលើសំណើសុំនេះ" ការសម្រេចនោះអាចត្រូវបានប្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤(៣)(ង) ដែលមានខ្លឹមសារថា[១៧]

"ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបសួរខាងក្រោម:

---

[១៦] "សេចក្តីសម្រេចលើសំណើសុំសវនាការផ្ទាល់មាត់សាធារណៈលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកា របស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ឯកសារ D140/4/4។

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៦ ដល់៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ក) [...]

ង) បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញ ដែលអនុញ្ញាតស្របតាម [វិធានផ្ទៃក្នុង] ទាំងអស់នេះ"។

១០. វិធាន ៣១(១០) នៃវិធានផ្ទៃក្នុង ចែងថា:

"សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់ពួកគេ អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញថ្មីបន្ថែមទៀត ដើម្បីធ្វើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលធ្វើរួចហើយ និងមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន។ សំណើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានបញ្ជាក់មូលហេតុ។ សំណើនេះត្រូវសម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមុនពេលបញ្ចប់ការស៊ើបសួរ ឬកិច្ចដំណើរការនីតិវិធី។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបដិសេធមិនព្រមធ្វើតាមសំណើ ដីកាបដិសេធនេះអាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ"។

១១. អង្គបុរេជំនុំជម្រះជូនដំណឹងថា សហចៅក្រមស៊ើបអង្កេតបានធ្វើការតែងតាំងអ្នកជំនាញពីររូបរួចហើយ រីឯសំណើសុំតែងតាំងអ្នកជំនាញបន្ថែម ជាសំខាន់ គឺផ្អែកលើការអះអាងរបស់សហមេធាវីដែលថា អ្នកជំនាញអន្តរជាតិដែលត្រូវបានតែងតាំង ខកខានមិនបានបំពេញលក្ខខណ្ឌសម្រាប់ការតែងតាំងនេះទេ។ វិធាន ៣១(១០) នៃវិធានផ្ទៃក្នុង បានចែងអំពីលក្ខខណ្ឌចំនួនពីរដែលអ្នកជំនាញបន្ថែមអាចត្រូវបានតែងតាំង។ លក្ខខណ្ឌទីមួយ គឺការដឹកនាំការត្រួតពិនិត្យដែលពីមុនមក មិនត្រូវបានធ្វើនោះទេ។ លក្ខខណ្ឌទីពីរ សំដៅលើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលធ្វើរួចហើយ និងមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន។

១២. នៅពេលដែលសំណើសុំដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ មានការតែងតាំង [redacted] ទៅហើយ ដែលរបាយការណ៍អ្នកជំនាញរបស់គាត់មិនទាន់បញ្ចប់នៅឡើយនាពេលនោះ។ របាយការណ៍របស់អ្នកជំនាញ ត្រូវបានដាក់ កាលពីថ្ងៃទី៣០ ខែកញ្ញា

ឆ្នាំ២០០៩ បន្ទាប់ពីបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីត្រូវបានដាក់។ អង្គបុរេជំនុំជម្រះយល់ឃើញថា ហេតុដូច្នេះ សំណើសុំដែលធ្វើដោយសហមេធាវីការពារក្ដី មិនធ្វើឡើងនៅក្នុងកម្រិតកំណត់នៃលក្ខខណ្ឌទីមួយ ដែលបានយោងនៅក្នុងវិធាន ៣១(១០) នៃវិធានផ្ទៃក្នុងនោះទេ នៅពេលដែលអ្នកជំនាញត្រូវបានតែងតាំងរួចហើយ ចំណែកឯសំណើសុំមិនមានការពាក់ព័ន្ធទៅនឹងអ្វី ដែលជា "ការដឹកនាំការត្រួតពិនិត្យថ្មី" នោះឡើយ។

១៣. ពាក់ព័ន្ធនឹងលក្ខខណ្ឌទីពីរស្របតាមវិធាន ៣១(១០)នៃវិធានផ្ទៃក្នុង ទាក់ទិននឹងការតែងតាំងអ្នកជំនាញបន្ថែមដើម្បី "ធ្វើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយ ដែលធ្វើរួចហើយ និងមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន" អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលដែលសំណើសុំ និងបណ្ដឹងឧទ្ធរណ៍ដែលបានផ្អែកលើការបដិសេធសំណើសុំនេះ ចុះថ្ងៃខែមុនរបាយការណ៍របស់អ្នកជំនាញ ពុំមានមូលដ្ឋានច្បាប់ចំពោះសំណើសុំនេះទេ។

១៤. បន្ទាប់ពីបានពិចារណាលើវិធាន៧៤(៣)(ង) យុត្តាធិការនៃអង្គបុរេជំនុំជម្រះក្នុងការកំណត់សម្រេចលើបណ្ដឹងឧទ្ធរណ៍ ត្រូវបានកំណត់ចំពោះការបដិសេធ "សំណើសុំបំពេញកិច្ចស៊ើបអង្កេតបន្ថែមណាមួយដោយអ្នកជំនាញ ដែលអនុញ្ញាតស្របតាមវិធានផ្ទៃក្នុងទាំងអស់នេះ"។ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ ដោយសារតែសំណើសុំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនត្រូវបានធ្វើឡើងប្រកបដោយសុពលភាព ស្របតាមវិធាន៣១(១០) នៃវិធានផ្ទៃក្នុងនោះទេ ហេតុនេះហើយសំណើសុំត្រូវបានធ្វើឡើងដោយគ្មានមូលដ្ឋានច្បាប់។

១៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងហាក់ដូចជាមិនមានចែង ពាក់ព័ន្ធនឹងបញ្ហាថាតើសំណើសុំអ្នកជំនាញបន្ថែមអនុលោមតាមវិធាន ៣១(១០) នៃវិធានផ្ទៃក្នុង ត្រូវយកទៅដាក់នៅមុន ឬក្រោយពេលដាក់របាយការណ៍ច្បាប់ដើមរបស់អ្នកជំនាញដែរឬទេ ជាពិសេសនៅពេលដែលវិធាននានាលើកឡើងអំពីការតែងតាំង "អ្នកជំនាញបន្ថែមដើម្បីដឹកនាំការត្រួតពិនិត្យថ្មី" នោះ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ពាក្យ"ថ្មី"នៅក្នុងប្រយោគនេះ ធ្វើឱ្យគេយល់ថា ភាពចាំបាច់

សម្រាប់ជំនាញការបន្ថែម ជាធម្មតានឹងកើតមានឡើង បន្ទាប់ពីការត្រួតពិនិត្យមួយចំនួនត្រូវបានធ្វើរួចហើយ។

១៦. អង្គបុរេជំនុំជម្រះយល់ឃើញថា យោងតាមច្បាប់កម្ពុជា វាមិនមែនជារឿងធម្មតាទេក្នុងការតែងតាំងអ្នកជំនាញបដិបក្ខ ឬអ្នកជំនាញបន្ថែម នៅមុនពេលដាក់របាយការណ៍របស់អ្នកជំនាញ។ ដូចនេះ មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមានចំណងជើងថា "ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ" បានចែងពាក់ព័ន្ធថា ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា "អំពីរបាយការណ៍នោះ" និងកោះហៅជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជូនដំណឹងដល់ពួកគេ "អំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ"។ បន្ទាប់មក ចៅក្រមស៊ើបសួរត្រូវកំណត់រយៈពេលដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ។

១៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បទដ្ឋាននីតិវិធីដែលបានបង្កើតនៅកម្រិតបទដ្ឋានអន្តរជាតិមិនមានចែងទេ នៅពេលដែលឈានមកដល់ការកំណត់សំណើសុំតែងតាំងអ្នកជំនាញបន្ថែម ទោះបីជាយ៉ាងណាក៏ដោយ វាបង្ហាញថា "ការតតាំងនឹងគុណវុឌ្ឍិនៃសាក្សីដែលជាអ្នកជំនាញ" ត្រូវបានអនុញ្ញាត តែក្រោយពេលផ្សព្វផ្សាយរបាយការណ៍របស់អ្នកជំនាញតែប៉ុណ្ណោះ។ ដូចនេះ នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ការកាត់សេចក្តីលើជនដែលទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងទឹកដីអតីតប្រទេសយូហ្គោស្លាវី (ICTY) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់ប្រទេសរ្វ៉ាន់ដា (ICTR) វិធានដែលពាក់ព័ន្ធនឹងអ្នកជំនាញ គឺវិធាន ៩៤ស្ទួន និងនៅតុលាការពិសេសសម្រាប់ប្រទេសលីបង់ (STL) ត្រូវបានចែងនៅក្នុងវិធាន ១៦១។ វិធាននៅក្នុងតុលាការនីមួយៗទាំងនេះមានលក្ខខណ្ឌស្រដៀងគ្នា ខ្លាំងណាស់។ វិធានតុលាការ ICTY ចែងដូចខាងក្រោម:

"វិធាន ៩៤ស្ទួន សក្ខីកម្មរបស់សាក្សីជាអ្នកជំនាញ

(ក) [...]

(ខ) នៅក្នុងរយៈពេល៣០ថ្ងៃនៃការផ្សព្វផ្សាយចម្លើយ និង/ឬ របាយការណ៍របស់សាក្សីជាអ្នកជំនាញ ឬពេលវេលាផ្សេងទៀត ដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមអង្គបុរេជំនុំជម្រះ ភាគីបដិបក្ខត្រូវដាក់សេចក្តីជូនដំណឹង ដែលបង្ហាញថា តើៈ

(i) ខ្លួនទទួលស្គាល់ចម្លើយ និង/ឬ របាយការណ៍របស់សាក្សីជាអ្នកជំនាញដែរឬទេ។ ឬក៏

(ii) ខ្លួនមានបំណងសួរដេញដោលសាក្សីជាអ្នកជំនាញដែរឬទេ។ និង

(iii) ខ្លួនតតាំងនឹងគុណវុឌ្ឍិរបស់សាក្សីជាអ្នកជំនាញ ឬភាពពាក់ព័ន្ធនឹងចម្លើយទាំងមូល ឬផ្នែកខ្លះនៃចម្លើយ និង/ឬ របាយការណ៍ ដែរឬទេ ហើយប្រសិនបើដូច្នេះមែន តើវាជាផ្នែកមួយណា។

(គ) [...]"។

១៨. អង្គបុរេជំនុំជម្រះយល់ឃើញថា បទបញ្ញត្តិនានានៅក្នុងវិធានផ្ទៃក្នុង គឺយោងតាមបទបញ្ញត្តិដែលបានបង្កើតឡើងនៅកម្រិតបទដ្ឋានអន្តរជាតិទាំងអស់នោះ។

១៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា សហមេធាវីលើកទឡ្ហីករណ៍ថា ការបដិសេធដោយសហចៅក្រមស៊ើបអង្កេតក្នុងការតែងតាំងអ្នកជំនាញបន្ថែម បានបំពានលើសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ។

២០. ពាក់ព័ន្ធនឹងបញ្ហានេះ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថាៈ

"វិធាន ២១: គោលការណ៍គ្រឹះ

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចនូវផលប្រយោជន៍របស់ជនសង្ស័យ

ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេស របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាន នូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ[...]"។

២១. អង្គបុរេជំនុំជម្រះនឹងត្រួតពិនិត្យ ថាតើវិធាន២១នៃវិធានផ្ទៃក្នុង កំណត់លក្ខខណ្ឌថា វិធាននេះបានបង្កើតនូវការបកស្រាយដែលកាន់តែទូលំទូលាយ អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីនៅក្នុងពេលស៊ើបអង្កេតមានភាពយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ និងធានាថា តុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយត្រូវបានរក្សាទុកដែរឬទេ។

២២. អង្គបុរេជំនុំជម្រះពិចារណាឃើញថា បទបញ្ញត្តិនានានៅក្នុងវិធានផ្ទៃក្នុង នៅតែអនុញ្ញាតឲ្យមេធាវីការពារក្តីស្នើសុំធ្វើការតែងតាំងអ្នកជំនាញមួយរូប ដើ ម្បីធ្វើការត្រួតពិនិត្យជាថ្មី ឬត្រួតពិនិត្យឡើងវិញលើបញ្ហាណាមួយដែលពេលនេះមានក្នុងរបាយការណ៍របស់អ្នកជំនាញមុន។ លើសពីនេះទៀតគេកត់សម្គាល់ឃើញថា របាយការណ៍នោះអាចយកមកធ្វើការជជែកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[១៨]។ បន្ថែមពីលើនេះទៀត នៅពេលដែលអង្គជំនុំជម្រះពិចារណាឃើញថាកិច្ចស៊ើបសួរថ្មីមានភាពចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យមានកិច្ចស៊ើបសួរបន្ថែមនៅពេលណាក៏បាន[១៩]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ យល់ឃើញថា ពុំមានសិទ្ធិជាមូលដ្ឋានរបស់មេធាវីការពារក្តី បានរងនូវការខូចខាតដោយសារការប្រកាសថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយក

[១៨] វិធាន ៨៧ នៃវិធានផ្ទៃក្នុង។

[១៩] វិធាន ៩៣(១) នៃវិធានផ្ទៃក្នុង។

អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បាន នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ។ ហេតុដូច្នេះ វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបង្គាប់ឲ្យអង្គបុរេជំនុំជម្រះយល់ព្រមតាមបណ្តឹងឧទ្ធរណ៍នោះទេ។

២៣. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ:**

ប្រកាសថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

ភ្នំពេញ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៩

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន័យ ចុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គីមសាន**